# សេចក្តីជូនដំណឹងអំពីការពិគ្រោះថ្លៃ

## សហគមន៍កសិកម្មទំនើបស្រូវវែងជ្រៃមានជ័យ

## មានបំណងអនុវត្តការងារសាងសង់ឃ្លាំងស្តុកទំហំ ១៥មx២៥មx៦មចំនួន ១ខ្នង

(១) សហគមន៍កសិកម្មទំនើប របស់យើងខ្ញុំបានទទួលមូលនិធិ ពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលផ្តល់ហិរញ្ញប្បទានដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ហើយមានគោលបំណងប្រើប្រាស់មូលនិធិនេះដើម្បីធ្វើការទូទាត់នៅក្រោមកិច្ចសន្យាសម្រាប់ការងារសាងសង់ឃ្លាំងស្តុកទំហំ ១៥មx២៥មx៦មចំនួន ១ខ្នង ត្រូវអនុវត្តទៅតាមប្រតិទិនការងារដូចមានរាយក្នុងទម្រង់ទី១៖ បញ្ជីប៉ាន់តម្លៃ និងប្រតិទិនការងារ។

(២) ការសាងសង់ឃ្លាំងស្តុក មានរយៈពេល ៣០ថ្ងៃ ចាប់ពីថ្ងៃបានចុះហត្ថលេខាលើកិច្ចសន្យា។

(៣) អ្នកទទួលកិច្ចការទាំងឡាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍ សូមអញ្ជើញមកទទួលឯកសារពិគ្រោះថ្លៃ (ដោយឥតគិតថ្លៃ) នៅសហគមន៍កសិកម្មទំនើបស្រូវស្រូវវែងជ្រៃមានជ័យ នៅការិយាល័យសហគមន៍កសិកម្មទំនើប អាស័យដ្ឋាន ភូមិប្រគាប ឃុំវែងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង លេខទូរស័ព្ទ ០៩៧៣៨៣៣១៤៣។ អ្នកទទួលកិច្ចការអាចទាក់ទងទៅឈ្មោះ ភិន ភារី ជាជំនួយការលទ្ធកម្ម តាមរយៈលេខទូរស័ព្ទ ០៧១៥៥៨១៥១៩។

(៤) ដើម្បីទទួលបានឯកសារពិគ្រោះថ្លៃ អ្នកទទួលការត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- ជាក្រុមហ៊ុនសំណង់ឯកជន ក្រុមជាងម៉ៅការសាងសង់នៅក្នុងសហគមន៍ ដែលមានអត្តសញ្ញាណសម្គាល់ច្បាស់លាស់ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (នៅមានសុពលភាព) មានបណ្ណប៉ាតង់ដែលមានសុពលភាព និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការសាងសង់/ផ្គត់ផ្គង់ទៅតាមបញ្ជីប៉ាន់តម្លៃ និងលក្ខណៈបច្ចេកទេសដែលបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។
- អ្នកទទួលកិច្ចការដែលត្រូវបានកំណត់ថាពាក់ព័ន្ធនឹងការក្លែងបន្លំ អំពើពុករលួយ និងអំពើឃុបឃិត ហើយស្ថិតក្នុងបញ្ជីហាមឃាត់ ក្នុងអំឡុងពេលធ្វើការដេញថ្លៃ នឹងមិនមានសិទ្ធិចូលរួមដេញថ្លៃឡើយ។
- អ្នកទទួលការត្រូវធ្លាប់បានបញ្ចប់កិច្ចសន្យាការងារសាងសង់ឃ្លាំង ឬការងារប្រហាក់ប្រហែល យ៉ាងតិចមួយដែលមានតម្លៃយ៉ាងតិច១០០%នៃតម្លៃឡូតិ៍មួយៗ ដែលបានដាក់ក្នុងសំណើពិគ្រោះថ្លៃ (សូមថតចម្លងកិច្ចសន្យា ភ្ជាប់ជាមួយសំណើពិគ្រោះថ្លៃ)។

(៥) សំណើពិគ្រោះថ្លៃ និងតម្លៃក្នុងសំណើពិគ្រោះថ្លៃ ត្រូវមានសុពលភាព និងជាតម្លៃថេរសម្រាប់រយៈពេល ៦០ ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់នៃការទទួលសំណើពិគ្រោះថ្លៃ។

(៦) តម្លៃសំណើពិគ្រោះថ្លៃត្រូវរួមបញ្ចូលនូវ ពន្ធអាករនានា ការដឹកជញ្ជូន ការធានារ៉ាប់រង និងចំណាយផ្សេងទៀត។

(៧) សំណើពិគ្រោះថ្លៃមិនអនុញ្ញាតិឱ្យមានការផ្លាស់ប្តូរឡើយ។

(៨) ការធានាលើគុណភាពសំណង់ត្រូវមានសុពលភាពយ៉ាងហោច ១២ខែ។

(៩) សំណើពិគ្រោះថ្លៃច្បាប់ដើមត្រូវតែចុះហត្ថលេខា ដោយអ្នកដែលទទួលបានសិទ្ធិពេញលេញដើម្បីចុះហត្ថលេខាជំនួសមុខឱ្យអ្នកពិគ្រោះថ្លៃ។ អ្នកពិគ្រោះថ្លៃត្រូវដាក់សំណើពិគ្រោះថ្លៃក្នុងស្រោមសំបុត្រមួយបិទជិត ហើយ បញ្ជូនឱ្យបានមុន ឬត្រឹមម៉ោង៖ ៣:០០រសៀល ថ្ងៃ២៣ ខែមីនា ឆ្នាំ២០២៦ ទៅសហគមន៍កសិកម្មទំនើប

Scanned with CamScanner

តវ៉ាដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃសំណើពិគ្រោះ ត្រូវបានពិនិត្យមើលដោយគណៈកម្មការលទ្ធកម្ម របស់សហគមន៍កសិកម្មទំនើប ហើយការឆ្លើយតប នឹងធ្វើឡើងបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ប៉ុណ្ណោះ។

ក្នុងករណីការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម មិនបានបំពេញតាមបំណងរបស់អ្នកពិគ្រោះថ្លៃចាញ់ ឬពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះទេ នោះអ្នកតវ៉ាត្រូវដាក់បណ្តឹងតវ៉ា ទៅកាន់ផ្នែករដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែម។ ផ្នែករដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែមត្រូវឆ្លើយតបការតវ៉ាក្នុងរយៈពេល ៧ថ្ងៃនៃប្រតិទិន។ ករណីនេះមិនបណ្តាលឱ្យមានការបាត់បង់សិទ្ធិរបស់អ្នកពិគ្រោះថ្លៃចំពោះការប្តឹងបន្តណាមួយផ្សេងទៀតដែលអ្នកពិគ្រោះថ្លៃអាចជ្រើសរើសនោះទេ។

(១៦) គោលការណ៍របស់សមាគមអភិវឌ្ឍន៍អន្តរជាតិតម្រូវឱ្យអ្នកខ្ចី (រួមទាំងអ្នកទទួលផលពីប្រាក់កម្ចីពីធនាគារ) អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលកិច្ចការ និងភ្នាក់ងាររបស់ពួកគេ (ទោះជាប្រកាស ឬមិនប្រកាស) អ្នកទទួលការបន្តអ្នកប្រឹក្សាបន្ទាប់ អ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់ និងបុគ្គលណាមួយ គោរពតាមស្តង់ដារខ្ពស់បំផុតនៃក្រមសីលធម៌វិជ្ជាជីវៈ ក្នុងអំឡុងពេលកិច្ចលទ្ធកម្មនិងក្នុងការអនុវត្តកិច្ចសន្យាដែលផ្តល់ហិរញ្ញប្បទានដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ។

(១៧) អ្នកទទួលកិច្ចការ អ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវាទាំងអស់ត្រូវអនុញ្ញាតិឱ្យសមាគមអភិវឌ្ឍន៍អន្តរជាតិ និង/ឬអ្នកដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិត្រួតពិនិត្យ ការដ្ឋាន គណនី និងឯកសារទាំងអស់ដែលទាក់ទងនឹងការអនុវត្តកិច្ចសន្យា និងការដាក់សំណើពិគ្រោះថ្លៃ ហើយគណនី និងកំណត់ត្រាទាំងនេះត្រូវបានធ្វើសវនកម្មដោយសវនករដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ប្រសិនបើត្រូវបានស្នើសុំដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ។

ប្រធានក្រុមប្រឹក្សាភិបាល
សហគមន៍កសិកម្មទំនើបស្រូវរូងជ្រៃមានជ័យ
ហត្ថលេខា

អ៊ិច សុខុម

Scanned with CamScanner

ស្រូវវង្សជ្រៃមានជ័យ អាស័យដ្ឋាន ភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង លេខទូរស័ព្ទ ០៩៧៣៨៣៣១៤៣។ អ្នកទទួលកិច្ចការអាចទាក់ទងទៅឈ្មោះ ភិន រ៉ាវី ជាជំនួយការលទ្ធកម្ម តាមរយៈ លេខទូរស័ព្ទ ០៧១៥៥៨១៥១៩។ សំណើពិគ្រោះដែលដាក់មកយឺតនឹងត្រូវបានបដិសេធ។ សំណើពិគ្រោះថ្លៃនឹងបើកឱ្យដាក់សំណើរជាសាធារណៈភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ឈប់ទទួលសំណើពិគ្រោះថ្លៃ នៅចំពោះមុខអ្នកតំណាងអ្នកពិគ្រោះថ្លៃ ដែលអាចចូលរួមដោយផ្ទាល់។

(១០)គ្រប់សំណើពិគ្រោះថ្លៃត្រូវភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃ ដូចមានចែងក្នុងឯកសារពិគ្រោះថ្លៃ។ សំណើពិគ្រោះថ្លៃដែលមិនបានភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃនឹងត្រូវបដិសេធ។

(១១)សំណើពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃដោយធ្វើការកែតម្រូវការភ័ន្តច្រឡំនៃការគណនា (លេខាគណិត) ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

(ក) នៅពេលដែលមានការខុសគ្នារវាងចំនួនទឹកប្រាក់ជាតួលេខ និងចំនួនទឹកប្រាក់ជាអក្សរ នោះចំនួនទឹកប្រាក់ជាអក្សរនឹងយកជាបានការ។

(ខ) នៅពេលដែលមានការខុសគ្នារវាងថ្លៃឯកតា និងតម្លៃសរុបនីមួយៗ ដែលបានមកពីផលគុណថ្លៃឯកតានឹងបរិមាណ នោះថ្លៃឯកតានឹងយកជាគោល។

ប្រសិនបើអ្នកពិគ្រោះថ្លៃបដិសេធមិនទទួលយកការកែតម្រូវ សំណើពិគ្រោះថ្លៃរបស់គេត្រូវបានបដិសេធ ហើយលិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបានអនុវត្ត។

(១២)សហគមន៍កសិកម្មទំនើប ត្រូវសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកពិគ្រោះថ្លៃណាដែលមានសំណើពិគ្រោះថ្លៃរបស់គេត្រូវបានកំណត់ថាមានការឆ្លើយតបច្រើន ស្របទៅតាមបទដ្ឋាន និងលក្ខណៈបច្ចេកទេស និងបានដាក់តម្លៃពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃថាទាបសមស្របជាងគេ។

(១៣)ក្នុងករណីមានភាពពិបាកណាមួយ ក្នុងការទទួលយកឯកសារពិគ្រោះថ្លៃ អ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមពិគ្រោះថ្លៃទាំងអស់ អាចជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីករណីពិបាកនោះទៅកាន់លោក អ៊ាង សុខុម ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្មទំនើប ទូរសព្ទលេខ **០៩៧ ៣៨៣ ៣១៤៣ អាសយដ្ឋាន ភូមិបល្ល័ងក្រោម ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង និងថតចម្លងផ្ញើជូនទៅ៖**

ផ្នែករដ្ឋបាលគ្រប់គ្រងទុនវិនិយោគបន្ថែម នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលមានអាសយដ្ឋាននៅជាន់ផ្ទាល់ដីរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាស័យដ្ឋាន៖#២០០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(១៤) បន្ទាប់ពីមានការសម្រេចប្រគល់កិច្ចសន្យាត្រូវបានប្រកាស អ្នកពិគ្រោះថ្លៃដែលបរាជ័យមានសិទ្ធិស្នើសុំឱ្យមានការពន្យល់ ដើម្បីឱ្យដឹងច្បាស់ពីមូលហេតុនៃការបរាជ័យនៃសំណើពិគ្រោះថ្លៃរបស់ខ្លួន ហើយគណៈកម្មការលទ្ធកម្មរបស់សហគមន៍កសិកម្មទំនើប មានកាតព្វកិច្ចផ្តល់ការពន្យល់បន្ថែម។ ព័ត៌មានចាំបាច់ផ្ទាល់ខ្លួនរបស់អ្នកពិគ្រោះថ្លៃត្រូវបានរក្សាជាការសម្ងាត់ មិនឱ្យភាគីផ្សេងទៀតបានដឹងឡើយ។

(១៥) បណ្តឹងតវ៉ាត្រូវបញ្ជូនទៅប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្មទំនើប។ ប្រធានក្រុមប្រឹក្សាភិបាលនឹងធ្វើការអង្កេតលើមូលដ្ឋាននៃការតវ៉ា និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៧ថ្ងៃនៃប្រតិទិនបន្ទាប់ពីទទួលបានបណ្តឹងតវ៉ានេះ លើកលែងតែក្នុងករណីការតវ៉ា ដែលបានទទួលក្នុងអំឡុងពេលវាយតម្លៃ។ ការ

Scanned with CamScanner